**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ: ..៩៤៤...... PC.អក

## សេចក្តីជូនដំណឹង
## ស្តីពី

ការផ្គត់ផ្គង់សាច់ក្រណាត់ឯកសណ្ឋាន ស្លាកឈ្មោះ និងស្លាកសញ្ញា ជូន ជាងចេញក្រៅ និងជាងរោងជាង នៃ អគ្គិសនីកម្ពុជា សម្រាប់ឆ្នាំ២០២២ (ភ្នំពេញនិងខេត្តចំនួន ១៥)

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា ៖ អគ្គិសនីកម្ពុជា នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់សាច់ក្រណាត់ឯកសណ្ឋាន ស្លាកឈ្មោះ និងស្លាកសញ្ញា ជូន ជាងចេញក្រៅ និងជាងរោងជាង នៃ អគ្គិសនីកម្ពុជា សម្រាប់ឆ្នាំ២០២២ (ភ្នំពេញនិងខេត្តចំនួន ១៥) ។

អគ្គិសនីកម្ពុជា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជា ដែលមានអាសយដ្ឋានៈ អាគារលេខ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញចាប់ពីថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០២២ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ៖ 023 67 66 007, 092 65 23 57 និង Website: www.edc.com.kh ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង ១៤:00 ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២២ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើវេលាម៉ោង ១៥:0៥ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២២ ។

ក្រុមហ៊ុន/សហគ្រាសដែលចូលរួមដាក់ឯកសារដេញថ្លៃ ស្នើសុំភ្ជាប់បន្ថែមមកជាមួយនូវឯកសារដេញថ្លៃ ដែលបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងភ្ជាប់មកជាមួយនូវ Soft Copy ដែលជាឯកសារ Scan របស់ឯកសារដេញថ្លៃនេះ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃពុធ ១១ រោច ខែ ចេត្រ ឆ្នាំ ខាល ចត្វាស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២២
**ស·ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ហាច់_ទូច**

ចម្លងជូន៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ